**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
លេខៈ២៧៥៥ អយក.ជារ

ថ្ងៃពុធ ៦កើត ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៥

# ជម្រាបជូន

**-ឯកឧត្តម លោកជំទាវ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ**
**-ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រធានអង្គភាពក្រោមឱវាទក្រសួង**
**-លោក លោកស្រី ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**

**កម្មវត្ថុ ៖** ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៦-២០២៨ និងបណ្តាឆ្នាំខាងមុខ របស់ក្រសួងអប់រំ យុវជន និងកីឡា។

**យោង ៖** សារាចរលេខ ០៨ សរ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៥ របស់រាជរដ្ឋាភិបាលកម្ពុជា។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប ឯកឧត្តម លោកជំទាវ លោក លោកស្រីប្រធាន ជ្រាបថា៖ ជារៀងរាល់ឆ្នាំរាជរដ្ឋាភិបាល តែងតែចេញនូវសារាចរ ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងកញ្ចប់ថវិកាប្រចាំឆ្នាំជូនក្រសួង ស្ថាប័ន ដែលជាឧបករណ៍ដ៏មានសារៈសំខាន់សម្រាប់ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់ក្រសួង ហើយក៏ជាមូលដ្ឋានដ៏រឹងមាំសម្រាប់ការរៀបចំនិងវិភាជថវិកាប្រចាំឆ្នាំឱ្យចំគោលដៅអាទិភាព។ ជាក់ស្តែង ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៦-២០២៨និងកញ្ចប់ថវិកាប្រចាំឆ្នាំ២០២៦ រាជរដ្ឋាភិបាល បានចេញសារាចរលេខ០៨ សរ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៥ ដោយក្នុងខ្លឹមសារនៃសារាចរនេះ ត្រង់ទំព័រទី១៦ ចំណុចទី៤.១ គឺគោលការណ៍និងបច្ចេកទេសនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៦-២០២៨ បានចែងថា "ក្រសួង ស្ថាប័ននីមួយៗ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិការួមមួយ ដែលគ្របដណ្តប់ទាំងថវិកាថ្នាក់កណ្តាល ថវិកាមន្ទីរជំនាញរាជធានី ខេត្ត និងថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលស្ថិតក្រោមឱវាទក្រសួង ស្ថាប័ន ព្រមទាំងថវិការបស់ថ្នាក់ក្រោមជាតិ(សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាលនិងវិស័យអប់រំ)" ដោយត្រូវធ្វើសមាហរណកម្មថវិកាចរន្តនិងថវិកាមូលធន ព្រមទាំងរវាងថវិកាជាតិនិងថវិកាដោយហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍ ដែលជាមូលដ្ឋានគ្រឹះដ៏រឹងមាំធ្វើឱ្យផែនការយុទ្ធសាស្ត្រថវិកាមានទម្ងន់និងគុណភាពល្អប្រសើរជាងមុន។

ដូចនេះ ដើម្បីធានាបាននូវការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៦-២០២៨ ឱ្យប្រកបដោយគុណភាពនិងភាពគ្រប់ជ្រុងជ្រោយ ហើយឆ្លើយតបនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០២៤-២០២៨ និងអាទិភាពនៃកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡាឆ្នាំ២០២៣-២០២៨ ផងដែរ។ ក្នុងន័យនេះ



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

ក្រសួងស្នើសូមឱ្យអង្គភាពក្រោមឱវាទក្រសួង ទាំងរដ្ឋបាលកណ្តាលនិងមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ត្រូវដាក់បញ្ចូលធនធានថវិការដ្ឋ(ចរន្តនិងមូលធន) ព្រមទាំងថវិកាដៃគូអភិវឌ្ឍនានាគ្រប់ប្រភព ដែលកំពុងចូលរួមជួយគាំទ្រសកម្មភាពអាទិភាពរបស់អង្គភាពនីមួយៗ ទៅក្នុងការរៀបចំផែនការយុទ្ធសាស្ត្រ ថវិកាឆ្នាំ២០២៦-២០២៨ ធ្វើយ៉ាងណាឱ្យមានភាពច្បាស់លាស់ ត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយ ដែលជាមូលដ្ឋាន បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុឱ្យកាន់តែមានតម្លាភាពនិងបន្ទាត់គណនេយ្យភាព ដោយឆ្លុះបញ្ចាំង តាមរយៈការអនុវត្តសកម្មភាពក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំនិងរបាយការណ៍សមិទ្ធកម្មរបស់អង្គភាពសាមី។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម លោកជំទាវ លោក លោកស្រីប្រធាន ជ្រាបនិង ចាត់ចែងអនុវត្ត ឱ្យប្រកបដោយស្មារតីទទួលខុសត្រូវនិងមានប្រសិទ្ធភាពខ្ពស់សម្រាប់ការរៀបចំផែនការ យុទ្ធសាស្ត្រថវិកាឆ្នាំ២០២៦-២០២៨ និងបណ្តាឆ្នាំខាងមុខ តាមការគួរ។

សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**ចម្លងជូនៈ**
-អគ្គលេខាធិការដ្ឋាន
-គ្រប់អគ្គនាយកដ្ឋាននិងអគ្គាធិការដ្ឋាន
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី
“ដើម្បីជូនជ្រាបជាព័ត៌មាន”
-កាលប្បវត្តិ
-ឯកសារ នាយកដ្ឋានហិរញ្ញវត្ថុ